អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន
## សេចក្តីថ្លែងការណ៍របស់លោក នីកូឡាស ខូមជៀន
## សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង០០៣

វិធាន៥៤ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) តម្រូវឲ្យដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមណាមួយក៏ដោយដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា គឺជាឯកសារសម្ងាត់។ ទោះជាយ៉ាងដូច្នេះក៏ដោយ ក៏វិធាននេះបានចែងផងដែរថា សហព្រះរាជអាជ្ញា "អាចផ្តល់ឲ្យសាធារណជននូវព័ត៌មានសង្ខេបដែលមាននៅក្នុងដីកាទាំងនេះ"។ ហេតុដូច្នោះហើយ ដោយគិតពិចារណាពីផលប្រយោជន៍សន្តិសុខ និងភាពលាក់កំបាំងរបស់ជនរងគ្រោះ និងសាក្សី, ពិចារណាពីសិទ្ធិស្តីពីសច្ចធារណ៍នៃនិរទោសរបស់ជនសង្ស័យដែលត្រូវទទួលបាន និងពិចារណាពីលក្ខខណ្ឌតម្រូវនានាដែលថា ការស៊ើបអង្កេតត្រូវធ្វើឡើងជាសម្ងាត់ សហព្រះរាជអាជ្ញាអន្តរជាតិសូមជម្រាបជូននូវព័ត៌មានដូចតទៅ ៖

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមួយក្នុងសំណុំរឿង០០៣ ដោយមានចេតនាសំខាន់ដកចេញនូវភាពដែលមានន័យមិនប្រាកដទាំងឡាយដែលទាក់ទងនឹងវិសាលភាពនៃដីកាសន្និដ្ឋានឲ្យស៊ើបសួរដំបូង។ ជាដំបូង សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការអះអាងជាថ្មីឡើងវិញនូវសេចក្តីបញ្ជាក់ ដែលបានដាក់ជូននៅក្នុងការដាក់ឯកសារនានាពីមុន ទាក់ទងនឹងឧក្រិដ្ឋកម្មផ្សេងៗដែលស្ថិតនៅក្នុង និងនៅក្រៅវិសាលភាពនៃការស៊ើបអង្កេត ហើយបន្ទាប់មក ធ្វើការបញ្ជាក់ពីលើនោះបន្ថែមទៀត។

សំណើមួយ ក៏ត្រូវបានធ្វើឡើងផងដែរ ដើម្បីដាក់បញ្ចូលនូវការស៊ើបអង្កេតលើឧក្រិដ្ឋកម្មនានាដែលអាចមានបន្ថែមទៀតនៅកំពង់សោម ដែលបានដឹងនៅក្រោយការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើសំណុំរឿង០០៣។ សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើដល់សហចៅក្រមស៊ើបអង្កេត សូមឲ្យធ្វើការពិចារណាលើឧក្រិដ្ឋកម្មបន្ថែមស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងភស្តុតាងដែលគូស្រករទាំងនេះត្រូវបានបង្ខំឲ្យមានទំនាក់ទំនងខាងផ្លូវភេទ (ការរំលោភសេពសន្ថវៈ)។ ឥឡូវនេះ ភស្តុតាងនានាដែលអាចរកបាន បង្ហាញថា មានឱកាសជាច្រើនដងដែលក្រុមគូស្រកររហូតដល់ទៅ ២០ (ម្ភៃ) គូ ត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍នៅក្នុងពិធីតែមួយ ហើយដែលក្រុមស្ត្រីទាំងនោះត្រូវបានបញ្ជូនមកពីភូមិភាគ ឬតំបន់ផ្សេងៗទៀត ឲ្យទៅកំពង់សោមដើម្បីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាមួយកម្មាភិបាលយោធា។

សហព្រះរាជអាជ្ញាអន្តរជាតិ សូមរំលឹកដល់សាធារណជនថា រាល់ជនសង្ស័យទាំងអស់ត្រូវមានសិទ្ធិស្តីពីសច្ចធារណ៍នៃនិរទោស ហើយសំណុំរឿង ០០៣ នេះគឺកំពុងស្ថិតនៅក្រោមការស៊ើបសួរនៅឡើយ។ ភស្តុតាងថ្មីៗត្រូវបានដឹងជាបន្តបន្ទាប់ ហើយក៏ដូចជាការអនុវត្តនៅក្នុងកិច្ចស៊ើបសួរករណីព្រហ្មទណ្ឌណាមួយ ដូច្នោះដែរ។ វាជាការសំខាន់ណាស់

ដែលត្រូវចៀសវាងនូវការធ្វើសេចក្តីសន្និដ្ឋានផ្សេងៗ រហូតទាល់តែកិច្ចស៊ើបសួរត្រូវបានបញ្ចប់ ហើយជនសង្ស័យ តាមរយៈមេធាវីការពារក្តីរបស់ខ្លួនត្រូវបានផ្តល់សិទ្ធិឲ្យបានស្តាប់ចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតជាមុនសិន។

ចុងបញ្ចប់នេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមទទួលស្គាល់នូវសេចក្តីក្លាហានរបស់សាក្សី និងជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយ ដែលបានមកផ្តល់ភស្តុតាងទាំងនេះ។ នៅក្នុងយុទ្ធនាការស្តីពីជម្លោះប្រដាប់អាវុធ និងអំពើឃោរឃៅនានានៅជុំវិញពិភពលោកនេះ វាគឺជាបាតុភូតដែលកើតឡើងដដែលជាដដែល ដែលអំពើហិង្សាលើផ្លូវភេទត្រូវបានរាយការណ៍មកយ៉ាងតិចបំផុត។ ជនរងគ្រោះទាំងឡាយ ដែលរងគ្រោះពីអំពើហិង្សាបែបនេះ បានទទួលរងនូវស្លាកស្នាមផ្លូវចិត្ត និងផ្លូវកាយ ពីឧក្រិដ្ឋកម្មទាំងនេះអស់មួយជីវិតរបស់ខ្លួន។ ដូច្នោះហើយ សហព្រះរាជអាជ្ញាអន្តរជាតិក៏ទទួលស្គាល់ផងដែរថា ករណីយកិច្ចដ៏សំខាន់ របស់អយ្យការដែលត្រូវតែធ្វើអ្វីៗគ្រប់យ៉ាងដែលខ្លួនអាចធ្វើបាន ដើម្បីធានាដល់កង្វល់ខាងសន្តិសុខរាងកាយ និងភាពលាក់កំបាំងរបស់ជនរងគ្រោះទាំងនេះត្រូវបានគោរព ហើយការពិតស្តីពីទុក្ខសោករបស់ពួកគាត់ត្រូវបានទទួលស្គាល់៕